ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យដំណើរការជាផ្លូវការច្រកចេញចូលតែមួយទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ គ្រប់អង្គភាព បុគ្គលិក មន្ត្រីរាជការ និង សាធារណជន មេត្តាជ្រាបថា ក្នុងគោលបំណងលើកកម្ពស់គុណភាព និងតម្លាភាព នៃការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋាន និងអង្គភាព ដែលបម្រើសេវាសាធារណៈនៅក្នុងទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមគោលការណ៍អភិបាលកិច្ចល្អ និងកម្មវិធីកែទម្រង់ របស់រាជរដ្ឋាភិបាល, ក្រសួង បានដាក់ឱ្យដំណើរការជាផ្លូវការ នូវច្រកចេញចូលតែមួយ ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈប្រកាសលេខ ១៨២៣ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីស្តង់ដារសេវាសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ប្រកាសលេខ ៣៨៩ សហវ.ប្រក ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃច្រកចេញចូលតែមួយទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជាក់ស្តែង ច្រកចេញចូលតែមួយទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានអគ្គនាយកដ្ឋាន និងអង្គភាព ក្រោមឱវាទក្រសួង ចំនួន០៣ ដែលមានទីតាំងស្ថិតនៅក្នុងទីស្តីការក្រសួងផ្ទាល់ បម្រើសេវាសាធារណៈ គឺ **អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានធនធានមនុស្សហិរញ្ញវត្ថុ**? **អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ**។ ដោយឡែក សេវាសាធារណៈដែលត្រូវបម្រើដោយអគ្គនាយកដ្ឋាន មានទីតាំងនៅខាងក្រៅទីស្តីការក្រសួង ចំនួន ០៣ ទៀត រួមមាន **អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** និង **អគ្គនាយកដ្ឋានរតនាគារជាតិ** ទទួលបន្ទុកផ្តល់សេវាជូនសាធារណជននៅទីតាំងផ្ទាល់របស់សាមីអង្គភាព តែម្តង។

ក្រសួងសូមបញ្ជាក់ជូនសាធារជន ថា ដើម្បីទទួលបានព័ត៌មានលម្អិតនានា ពាក់ព័ន្ធការផ្តល់សេវាសាធារណៈ ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុ, សាធារណជន អាចចូលទៅពិនិត្យលើកម្រងសេវាសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈគេហទំព័ររបស់ក្រសួង, គេហទំព័រអគ្គលេខាធិការដ្ឋានក្រសួង និងគេហទំព័ររបស់អគ្គនាយកដ្ឋាន និងអង្គភាពមួយចំនួនទៀត ក្រោមឱវាទក្រសួង។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានការរំពឹងទុកយ៉ាងមុតមាំថា ការដាក់ឱ្យដំណើការនូវច្រកចេញចូលតែមួយទីស្តីការក្រសួង នេះ នឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយសម្រួល និងជំរុញនីតិវិធីការងារ ក៏ដូចជាផ្តល់ភាពងាយស្រួលដល់សាធារណជន អាចមកទទួលសេវាសាធារណៈពីក្រសួង ដោយរលូន ទាន់ពេល និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងអាចបំពេញសេចក្តីត្រូវការជូនសាធារណជន បានល្អប្រសើរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមគ្រប់អង្គភាព បុគ្គលិក មន្ត្រីរាជការ និងសាធារណជនទាំងអស់ មេត្តាជ្រាប និងសហការអនុវត្ត តាមការគួរ ព្រមទាំងចូលរួមផ្តល់មតិយោបល់កែលម្អការងារ នៅតាមដំណាក់កាលជាបន្តបន្ទាប់ទៀត ដើម្បីគាំទ្រដល់ការផ្តល់សេវាសាធារណៈរបស់ក្រសួង កាន់តែទទួលបានការវាយតម្លៃខ្ពស់ និងភាពពេញចិត្តពីសាធារណជន។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៧

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855 23 724 664 Fax : 855 23 427 798